**អនុម័ត**

# សេចក្តីសម្រេចចិត្ត
# នៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
# លើកទី២ ឆ្នាំ២០២៤
## ថ្ងៃពុធ ៥រោច ខែកត្តិក ឆ្នាំរោង ឆស័ក ពុទ្ធសករាជ ២៥៦៨
## ត្រូវនឹងថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤

កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ ឆ្នាំ២០២៤ បានដំណើរការរយៈពេលមួយព្រឹកពេញ នាថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ នៅសាលប្រជុំ «D» អគារមិត្តភាព ទីស្តីការគណៈរដ្ឋមន្ត្រី ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុមការងារប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ស្ថាប័ន លេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្តទាំង២៥ អង្គការអន្តរជាតិ និងអង្គការសង្គមស៊ីវិល មានចំនួនសរុបប្រមាណ២០៤រូប។

អង្គប្រជុំទាំងមូលបានអបអរសាទរ ប្រកបដោយមោទនភាពជាមួយនឹងការសម្រេចបាននូវសមិទ្ធផលជាតិដ៏ធំធេងក្នុងឆ្នាំទីមួយរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ក្រោមកិច្ចដឹកនាំប្រកបដោយគតិបណ្ឌិត ឈ្លាសវៃ និងស្វាហាប់នៃ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** តាមរយៈការដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ព្រមទាំងកម្មវិធីគោលនយោបាយអាទិភាពចំនួន ៦ និងវិធានការគន្លឹះចំនួន ៥។

ជាមួយគ្នានេះ អង្គប្រជុំក៏បានថ្លែងអំណរគុណ និងកោតសរសើរចំពោះគ្រប់ក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អង្គការជាតិ អន្តរជាតិ សង្គមស៊ីវិល បណ្តាញអ្នកផ្ទុកមេរោគអេដស៍ និងបណ្តាញក្រុមប្រជាជនគន្លឹះ ដែលបានប្រឹងប្រែងបន្តចូលរួមយ៉ាងសកម្មក្នុងការងារឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា។

បន្ទាប់ពីការពិភាក្សាផ្លាស់ប្តូរយោបល់ដ៏ទូលំទូលាយមក កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ ឆ្នាំ២០២៤ បានដាក់ចេញនូវការសម្រេចចិត្ត ដូចតទៅ៖

១- ចូលរួមអនុវត្តឱ្យបានជោគជ័យនូវគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ របស់រាជរដ្ឋាភិបាលកម្ពុជា។

២- ទីស្តីការគណៈរដ្ឋមន្ត្រី និងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍សម្របសម្រួលការអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ ឱ្យមានប្រសិទ្ធភាពខ្ពស់។

៣- ក្រសួង ស្ថាប័ន រាជធានី ខេត្តត្រូវបង្កើនការផ្សព្វផ្សាយឱ្យយល់ដឹងអំពីហានិភ័យនៃមេរោគអេដស៍ដល់ប្រជាជនទូទៅតាមវិស័យរៀងៗខ្លួន ដើម្បីប្រកាន់ខ្ជាប់នូវវិធានការបង្ការការឆ្លងរាលដាលមេរោគអេដស៍ ជាពិសេសក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងព័ត៌មាន ។

៤- គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ស្ថាប័ន រាជធានី ខេត្ត ត្រូវខិតខំស្វែងរកអ្នកសង្ស័យថាផ្ទុកមេរោគអេដស៍ប្រមាណជិត៧ ០០០នាក់ដែលមិនទាន់ដឹងពីស្ថានភាពមេរោគអេដស៍ និងទាក់ទាញពួកគេឱ្យមកធ្វើតេស្តមេរោគអេដស៍។

៥- ក្រសួងសុខាភិបាលបន្តៈ

- កាត់បន្ថយការចម្លងមេរោគអេដស៍ពីម្តាយទៅកូនឱ្យធ្លាក់ដល់កម្រិតតិចជាង៥ភាគរយ ដើម្បីសម្រេចបានគោលដៅលុបបំបាត់ការចម្លងមេរោគអេដស៍ពី ម្តាយទៅកូន។
- ជំរុញបញ្ចូលសេវាថែទាំមេរោគអេដស៍ ទៅក្នុងប្រព័ន្ធសុខាភិបាលទាំងស្រុង រួមមានការបង្កើនចំនួនទីតាំងធ្វើតេស្ត និងធានាបានការព្យាបាលដល់គ្រប់អ្នកមានលទ្ធផលវិជ្ជមានមេរោគអេដស៍។
- ជំរុញមូលដ្ឋានសុខាភិបាលឯកជនឱ្យផ្តល់របាយការណ៍ស្តីពីការធ្វើតេស្ត និងព្យាបាលជំងឺអេដស៍ដើម្បីដាក់បញ្ចូលព័ត៌មានក្នុងប្រព័ន្ធទិន្នន័យរបស់ក្រសួងសុខាភិបាល។

៦- ចំពោះអ្នកផ្ទុកមេរោគអេដស៍ដែលជាអនីតិជន ក្រសួងសុខាភិបាលត្រូវបង្កើនសេវាថែទាំព្យាបាលជំងឺអេដស៍ដល់កុមារផ្ទុកមេរោគអេដស៍ ដោយយកផលប្រយោជន៍របស់ពួកគេជាមូលដ្ឋាន។ ក្នុងករណីមានការព្រមព្រៀងពីអនីតិជន ហើយការធ្វើតេស្តរកមេរោគអេដស៍ផ្តល់អត្ថប្រយោជន៍ផ្ទាល់ចំពោះអនីតិជន ក្រសួងសុខាភិបាលត្រូវណែនាំឱ្យអ្នកផ្តល់សេវាធ្វើតេស្តនោះធ្វើបាន ដោយពុំចាំបាច់មានការយល់ព្រមពីអាណាព្យាបាលឡើយ។

៧- គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត ប្រើប្រាស់កញ្ចប់ថវិកាជាតិសម្រាប់គណៈកម្មាធិការអេដស៍រាជធានីខេត្ត និងថវិកាដទៃទៀតក្នុងៈ

- ការបង្កើត ឬធ្វើបច្ចុប្បន្នភាពគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ គ្រប់ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដោយមានបញ្ចូលតំណាងអ្នកផ្ទុកមេរោគអេដស៍ និងប្រជាជនគន្លឹះ ក្នុងករណីចាំបាច់ ឱ្យបានត្រឹមត្រីមាសទីមួយ ឆ្នាំ២០២៥។
- សម្របសម្រួលអន្តរាគមន៍បង្ការ ពង្រឹងកម្មវិធីស្រោមនាម័យ១០០% ការផ្តល់សេវាមេត្រី នៃគ្លីនិកសុខភាពគ្រួសារ បរិយាកាសគាំទ្រ និងការធ្វើតេស្តរកមេរោគអេដស៍ ផ្តោតលើប្រជាជនដែលមានហានិភ័យខ្ពស់ ជាអាទិ៍ក្រុមយុវវ័យបុរសរួមភេទជាមួយបុរស។
- ធ្វើឱ្យសម្រេចការចុះបញ្ជីផ្តល់បណ្ណមូលនិធិសមធម៌សុខាភិបាល ដល់ក្រុមប្រជាជនគន្លឹះឱ្យបាន៥០% នៅដំណាច់ឆមាសទី១ ឆ្នាំ២០២៥ ដោយសហការជាមួយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ទីរទេសចរណ៍ បេឡាជាតិសន្តិសុខសង្គមសាខាខេត្ត ខណ្ឌ និងអាជ្ញាធរមានសមត្ថកិច្ច។

○ បង្កើនសមត្ថភាពគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រុង ស្រុក ខណ្ឌឱ្យបានយល់ដឹង និងអនុវត្តគោលការណ៍បង្ការដាក់លាក់ (ចំប្រជាជនគោលដៅ ចំទីតាំង ចំពេលវេលា ប្រើអន្តរាគមន៍សមស្រប ប្រើប្រាស់ទិន្នន័យ និងប្រើធនធានវៃឆ្លាត) ដើម្បីរៀបចំផែនការសកម្មភាព និងវិភាជថវិកាសម្រាប់ឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។

៨- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ រៀបចំបង្កើតក្រុមការងារជានាចីរភាពដែលមានសមាសភាពពីក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីជំរុញការអនុវត្តន៍ផែនទីបង្ហាញផ្លូវចីរភាពនៃការឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ ឆ្នាំ២០២៣-២០២៩។

ថ្ងៃពុធ ៥រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤

**ប្រធានអង្គប្រជុំ**

**ទេសរដ្ឋមន្ត្រី**

**ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**